**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០៧៧៧/១៦ ភ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្ដីជូនដំណឹង ស្ដីពី
# យុទ្ធនាការស្រលាញ់ប្រាក់រៀល

ធនាគារជាតិនៃកម្ពុជាមានសេចក្ដីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ដើម្បីគាំទ្រគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល លើកទឹកចិត្តប្រជាពលរដ្ឋគ្រប់រូបឱ្យប្រើប្រាស់រូបិយវត្ថុជាតិកាន់តែច្រើន ក៏ដូចជាចូលរួមចំណែកអបអរសាទរចំពោះពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីខ្មែរ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធររូបិយវត្ថុ នឹងរៀបចំយុទ្ធនាការស្រលាញ់ប្រាក់រៀល ចាប់ពីថ្ងៃទី២៦-៣០ ខែកញ្ញា ឆ្នាំ២០១៦ ។

យុទ្ធនាការនេះ នឹងផ្ដល់ឱកាសដល់ប្រជាជនគ្រប់រូប ដែលកំពុងមានក្រដាសប្រាក់រៀលចាស់ ទក់ និង/ឬ រហែក ឱ្យមកប្ដូរយកក្រដាសប្រាក់ថ្មីពីធនាគារជាតិនៃកម្ពុជា ។ ការប្ដូរក្រដាសប្រាក់នេះ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦-៣០ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១៥:០០ ដល់ម៉ោង ១៧:០០ នៅគ្រប់សាខារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្ដាល) របស់ធនាគារជាតិនៃកម្ពុជាជារៀលរាល់ថ្ងៃធ្វើការ ។

ឆ្លៀតក្នុងឱកាសនៃពិធីបុណ្យភ្ជុំបិណ្ឌនេះ ធនាគារជាតិនៃកម្ពុជា សូមជូនពរ សម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រីទាំងអស់ ឱ្យបានជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**អគ្គបេឡា**

ចាន់ យ៉ាន់

ទំនាក់ទំនងមកកាន់ធនាគារជាតិនៃកម្ពុជា ៖
www.facebook.com/nationalbankofcambodiaofficial
www.twitter.com/nbccambodia
www.youtube.com/nationalbankofcambodia

ទូរស័ព្ទ ៖១៩៦ ៩៩០ (២៣-៨៥៥)
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

ប្រអប់សំបុត្រលេខ ២៥, ទីតាំងលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧